ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់សាកលវិទ្យាល័យឌីជីថលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៧១ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា១០ថ្មី មាត្រា១៤ថ្មី មាត្រា១៥ថ្មី និងមាត្រា១៦ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ មាត្រា១៣ថ្មី មាត្រា៣០ថ្មី និងមាត្រា១១ថ្មីស្ទួន នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ និងមាត្រា៦១នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ .-**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយដែលមានឈ្មោះថា សាកលវិទ្យាល័យឌីជីថលកម្ពុជា សរសេរជាអក្សរកាត់ថា **ស.ឌ.ក**. និងជាភាសាអង់គ្លេសថា DIGITAL UNIVERSITY OF CAMBODIA សរសេរជាអក្សរកាត់ថា DUC។

**មាត្រា២ .-**

**ស.ឌ.ក**. ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន មានអាសយដ្ឋានស្ថិតនៅផ្លូវជាតិលេខ៣ ភូមិត្រពាំងស្លា ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣ .-**

**ស.ឌ.ក**. ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រនិងបរិញ្ញាបត្ររង ដែលមានមហាវិទ្យាល័យចំនួន៥ និងមានរចនាសម្ព័ន្ធដូចខាងក្រោម៖

**១- មហាវិទ្យាល័យឧស្សាហកម្មឌីជីថល**

ក- ដេប៉ាតឺម៉ង់ក្រាហ្វិកឌីហ្សាញ
- មុខជំនាញក្រាហ្វិកឌីហ្សាញ។

ខ- ដេប៉ាតឺម៉ង់ទីផ្សារឌីជីថល
- មុខជំនាញទីផ្សារឌីជីថល។

គ- ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយសង្គម
- មុខជំនាញប្រព័ន្ធផ្សព្វផ្សាយសង្គម។

**២- មហាវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រនយោបាយ**

ក- ដេប៉ាតឺម៉ង់នីតិសាស្ត្រ
- មុខជំនាញនីតិសាធារណៈ
- មុខជំនាញនីតិឯកជន
- មុខជំនាញនីតិពាណិជ្ជកម្មអន្តរជាតិ។

ខ- ដេប៉ាតឺម៉ង់រដ្ឋបាលសាធារណៈ
- មុខជំនាញរដ្ឋបាលសាធារណៈ។

គ- ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រនយោបាយ
- មុខជំនាញវិទ្យាសាស្ត្រនយោបាយ។

**៣- មហាវិទ្យាល័យកសិកម្មនិងអភិវឌ្ឍន៍ជនបទ**

ក- ដេប៉ាតឺម៉ង់ក្សេត្រសាស្ត្រនិងសាកវប្បកម្ម

- មុខជំនាញក្សេត្រសាស្ត្រនិងសាកវប្បកម្ម។

ខ- ដេប៉ាតឺម៉ង់សេដ្ឋកិច្ចកសិកម្ម

- មុខជំនាញសេដ្ឋកិច្ចកសិកម្ម។

គ- ដេប៉ាតឺម៉ង់អភិវឌ្ឍន៍ជនបទ

- មុខជំនាញអភិវឌ្ឍន៍ជនបទ។

**៤- មហាវិទ្យាល័យវិស្វកម្មនិងស្ថាបត្យកម្ម**

ក- ដេប៉ាតឺម៉ង់វិស្វកម្ម

- មុខជំនាញវិស្វកម្មសំណង់ស៊ីវិល។

ខ- ដេប៉ាតឺម៉ង់ស្ថាបត្យកម្ម

- មុខជំនាញស្ថាបត្យកម្ម។

គ- ដេប៉ាតឺម៉ង់រចនាផ្ទៃខាងក្នុង

- មុខជំនាញរចនាផ្ទៃខាងក្នុង។

**៥- មហាវិទ្យាល័យភាសាអង់គ្លេស**

ក- ដេប៉ាតឺម៉ង់ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងធុរកិច្ច

- មុខជំនាញភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងធុរកិច្ច។

ខ- ដេប៉ាតឺម៉ង់អប់រំភាសាអង់គ្លេស

- មុខជំនាញបង្រៀនភាសាអង់គ្លេស។

គ- ដេប៉ាតឺម៉ង់ភាសាអង់គ្លេសសម្រាប់ការបកប្រែ

- មុខជំនាញភាសាអង់គ្លេសសម្រាប់ការបកប្រែ។

ក្នុងករណីចាំបាច់ដែល **ស.ឧ.ភ.** ផ្លាស់ប្តូរទីតាំង បង្កើតសាខាថ្មី មហាវិទ្យាល័យថ្មី ដេប៉ាតឺម៉ង់ថ្មី មុខជំនាញថ្មី កម្រិតបណ្តុះបណ្តាលថ្មី ឬរៀបចំរចនាសម្ព័ន្ធមហាវិទ្យាល័យថ្មី ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤ .-**

**ស.ឧ.ភ.** មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីត្រួតពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធផ្សេងៗទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃ **ស.ឧ.ភ.** ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥ .-**

សាកលវិទ្យាធិការនៃ **ស.ឧ.ភ.** មានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រង **ស.ឧ.ភ.** និងធានាឱ្យមានសុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិត ការទទួលនិស្សិតឱ្យចូលរៀន និងការបញ្ចប់ការសិក្សា ស្របតាមកម្មវិធីសិក្សារបស់ **ស.ឧ.ភ.** និងបទដ្ឋាននិងគោលការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំកម្មវិធីសិក្សាលម្អិតឱ្យស្របតាមលក្ខខណ្ឌនិងបទប្បញ្ញត្តិនៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា

- គោរព និងអនុវត្តតាមបទដ្ឋាននិងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំឧត្តមសិក្សា
- រៀបចំរបាយការណ៍ប្រចាំឆ្នាំអំពីការងារបណ្តុះបណ្តាលជូនក្រសួងអប់រំ យុវជន និងកីឡា នៅក្រោយដំណាច់ឆមាសទី២។

**មាត្រា៦ .-**

និស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលសញ្ញាបត្រតាមកម្រិតនិងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយ **ស.ឌ.ក.** ផ្អែកលើបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាប់ជាស្ថាពរ ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យឌីជីថលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣កើតខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ មីនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកំពង់ស្ពឺ
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ